ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# កម្មវិធីវិនិយោគសាធារណៈ

# ៣ឆ្នាំរំកិល

# ២០២២ - ២០២៤

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ

នាថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១

រៀបចំដោយក្រសួងផែនការ

# អារម្ភកថា

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍បញ្ជាក់ឱ្យដឹងថា ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.)២០១៩-២០២៣*** គឺជាឯកសារសំខាន់មួយសម្រាប់គ្រប់គ្រងការវិនិយោគនិងការអភិវឌ្ឍលើវិស័យសាធារណៈនៅកម្ពុជា។

ចាប់តាំងពីឆ្នាំ១៩៩៦ ក្រសួងផែនការជាអ្នកទទួលខុសត្រូវក្នុងការរៀបចំ***កម្មវិធីវិនិយោគសាធារណៈ (ក.វ.ស) ៣ឆ្នាំរំកិល*** ជារៀងរាល់ឆ្នាំ ដើម្បីឆ្លើយតបទៅនឹងអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់តម្រូវការជំនួយវិនិយោគជាទុន និងជំនួយបច្ចេកទេសក្នុងការអនុវត្ត**ផ.យ.អ.ជ.**។ ក្នុងការរៀបចំ***ក.វ.ស. ៣ឆ្នាំរំកិល*** ចាប់ផ្ដើមពីឆ្នាំ២០០៦-២០០៨ មកដល់ឆ្នាំ២០២២-២០២៤នេះ ការវិភាជថវិកាបាននិងកំពុងឆ្លើយតបទៅនឹងការវិភាជដែលមានចែងនៅក្នុង***ផ.យ.អ.ជ.២០០៦-២០១០ ផ.យ.អ.ជ.បច្ចុប្បន្នកម្ម២០០៩-២០១៣ ផ.យ.អ.ជ.២០១៤-២០១៨ និងផ.យ.អ.ជ. ២០១៩-២០២៣***។

ក្រសួងផែនការបានបន្តធ្វើការកែសម្រួលបន្ថែមទៀតលើដំណើរការរៀបចំ***ក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤*** ដោយបានរៀបចំការពិភាក្សាដោយផ្ទាល់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងបណ្ដាក្រសួងស្ថាប័ននីមួយៗ ដើម្បីធានាថាការផ្ញើទិន្នន័យគម្រោងរបស់បណ្ដាក្រសួងស្ថាប័នទាំងអស់សម្រាប់ រៀបចំ***ក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤***បានឆ្លើយតបទៅនឹងអាទិភាពរបស់***ផ.យ.អ.ជ.២០១៩-២០២៣***។

***ផ.យ.អ.ជ.២០១៩-២០២៣*** បានចែងយ៉ាងច្បាស់លាស់ពីទំនាក់ទំនងនៃ***ផ.យ.អ.ជ. ក.វ.ស.៣ឆ្នាំរំកិល ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងថវិកាប្រចាំឆ្នាំ***។ បច្ចុប្បន្ននេះ ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា បាននិងកំពុងបន្តសម្របសម្រួលនិងប្រឹងប្រែងទាំងអស់គ្នាដើម្បីធានាបាននូវសុខដុមនីយកម្មការងារផែនការចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ។

ខ្ញុំមានសេចក្ដីរីករាយនិងសូមធ្វើការបង្ហាញនូវ***ក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤*** សម្រាប់ជាព័ត៌មាន និងការប្រើប្រាស់របស់រាជរដ្ឋាភិបាលកម្ពុជានិងទាំងដៃគូអភិវឌ្ឍទាំងអស់។ ខ្ញុំសូមឆ្លៀតយកឱកាសនេះ ដើម្បីបញ្ជាក់ឡើងវិញម្ដងទៀតនិងជំរុញដល់ដៃគូអភិវឌ្ឍដែលផ្ដល់ការជួយឧបត្ថម្ភគាំទ្រដល់ប្រទេសកម្ពុជាត្រូវមានមូលដ្ឋានពិនិត្យលើគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.នៃបញ្ជីគម្រោង***ក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤*** ដែលនឹងនាំយើងឈានទៅសម្រេចបាននូវគោលបំណងនិងអាទិភាពដែលមានចែងនៅក្នុង***ផ.យ.អ.ជ.២០១៩-២០២៣*** និងដើម្បីកាត់បន្ថយភាពក្រីក្រនិងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

**ក្រសួងផែនការ**

ខែតុលា ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងផែនការ**

**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

# សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា





# មាតិកា

ទំព័រ


អារម្ភកថា ........................................ i

សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ........................................ ii

មាតិកា ........................................ iii

ជំពូកទី១- សេចក្តីផ្តើម ........................................ ១

ក- ដំណើរការសុខដុមនីយកម្មការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋនិងហិរញ្ញប្បទានសហប្រតិបត្តិការ ........................................ ១

ខ- វិធីសាស្ត្រសម្រាប់រៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០២២-២០២៤ ........................................ ២

ជំពូកទី២-ទស្សនវិស័យសេដ្ឋកិច្ចឆ្នាំ២០២២-២០២៤ ........................................ ៦

ក- ស្ថានភាពទូទៅនៃកំណើនផលិតផលក្នុងស្រុកសរុប២០២២-២០២៤ ........................................ ៦

ខ- អត្រាកំណើនផ.ស.ស.ពិត(ថ្លៃថេរឆ្នាំ២០០០)តាមវិស័យ ........................................ ៧

គ- ការវិនិយោគដែលចាំបាច់ដើម្បីសម្រេចនូវកំណើនផ.ស.ស.ដែលបានគ្រោងទុក ........................................ ៨

ឃ- ចំណូលនិងចំណាយថវិកា២០២២-២០២៤ ........................................ ១១

ង- ចំណុចដៅនៃការកៀរគរធនធានសម្រាប់ការវិនិយោគរបស់វិស័យសាធារណៈឆ្នាំ២០២២-២០២៤ ១២

ជំពូកទី៣- កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០២២-២០២៤ ........................................ ១៥

ជំពូកទី៤- សេចក្តីសន្និដ្ឋាន ........................................ ៤៥


## បញ្ជីតារាង


តារាងទី១- ការព្យាករពីសូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច ........................................ ៧

តារាងទី២- អត្រាកំណើនផ.ស.ស.(ថ្លៃថេរឆ្នាំ២០០០)តាមវិស័យ ........................................ ៧

តារាងទី៣- ការវិនិយោគមូលធនចាំបាច់ដើម្បីសម្រេចបានកំណើនផ.ស.ស.ដែលបានគ្រោងទុកនិងធនធានដែលអាចមានសម្រាប់ធ្វើហិរញ្ញប្បទានដល់ការវិនិយោគចាំបាច់ ........................................ ៩

តារាងទី៤ : ការប៉ាន់ស្មានត្រូវការវិនិយោគមូលធនប្រចាំឆ្នាំតាមវិស័យ (តម្លៃបច្ចុប្បន្ន) ........................................ ១០

តារាងទី៥- ចំណុចដៅនៃការកៀរគរធនធានសម្រាប់ការវិនិយោគរបស់វិស័យសាធារណៈឆ្នាំ២០២២-២០២៤ ........................................ ១៣

តារាងទី៦- ការវិភាជតាមវិស័យនិងអនុវិស័យសម្រាប់តម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈដោយមានមូលដ្ឋានពីការវិភាជតាមវិស័យនិងអនុវិស័យ ចែងនៅក្នុងផ.យ.អ.ជ.២០១៩-២០២៣ .... ១៤

តារាងទី៧- ការវិភាជតាមវិស័យនិងអនុវិស័យសម្រាប់តម្រូវការវិនិយោគវិស័យសាធារណៈ ចែងនៅក្នុងផ. យ. អ. ជ. ២០១៩-២០២៣ និងក. វ. ស. ៣ឆ្នាំរំកិល២០២២-២០២៤ ............................ ១៦

តារាងទី៨- សេចក្តីសង្ខេបស្តីពីគម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ. យ. អ. ជ. ដែលក្រសួង ស្ថាប័នស្នើសុំសម្រាប់ក. វ. ស. ៣ឆ្នាំរំកិល២០២២-២០២៤ ...................................... ១៩

តារាងទី៩- គម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ. យ. អ. ជ. បែងចែកតាមវិស័យអាទិភាពនៃផ. យ. អ. ជ. ២០១៩-២០២៣ ដែលក្រសួងស្ថាប័នស្នើសុំ ............................................... ២០

តារាងទី១០- បរិមាណខុសគ្នានៃការវិភាជតាមអនុវិស័យផ. យ. អ. ជ. ២០១៩-២០២៣ និងការស្នើសុំដោយក្រសួងស្ថាប័ន ........................................................................................... ៤០

តារាងទី១១- សេចក្តីសង្ខេបការវិភាជតាមវិស័យក្នុងផ. យ. អ. ជ. ២០១៩-២០២៣និងចំណាយប៉ាន់ស្មានតាមក្រសួងស្ថាប័ន .................................................................................................. ៤១

តារាងទី១២- បញ្ជីគម្រោងបែងចែកតាមក្រសួងស្ថាប័ន ................................................... ៤៦

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ : ពាក្យបំប្រួញ ............................................................................................. V

# ឧបសម្ព័ន្ធទី១ : ពាក្យបំប្រួញ

| | |
|---|---|
| ក.វ.ស. | កម្មវិធីវិនិយោគសាធារណៈ |
| ផ.យ.អ.ជ. | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប |
| គ.ម. | គីឡូម៉ែត្រ |
| ADB | Asian Development Bank<br>ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFD | Agence Française de Développement (French Development Agency)<br>ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| AIF | Asean Infrastructure Fund<br>មូលនិធិហេដ្ឋារចនាសម្ព័ន្ធអាស៊ាន |
| AIIB | Asean Infrastructure Investment Bank<br>ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ាន |
| Belgium | Government of Belgium<br>រដ្ឋាភិបាលបែលហ្ស៊ិក |
| China | Government of China<br>រដ្ឋាភិបាលចិន |
| CIF | Climate Investment Fund<br>មូលនិធិវិនិយោគអាកាសធាតុ |
| DFID | Department for International Development<br>នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ |
| DPs | Development Partners<br>ដៃគូអភិវឌ្ឍ |
| EIB | European Investment Bank<br>ធនាគារវិនិយោគអឺរ៉ុប |
| EU/AIF | European Union/Asia Investment Facility<br>សហភាពអឺរ៉ុប/មូលនិធិវិនិយោគអាស៊ី |
| EU/EC | European Union/European Commission<br>សហភាពអឺរ៉ុប/គណៈកម្មការអឺរ៉ុប |
| FAO | Food and Agriculture Organization<br>អង្គការស្បៀងអាហារនិងកសិកម្ម |

| | |
|---|---|
| France | Government of France<br>រដ្ឋាភិបាលបារាំង |
| FHF | The Fred Hollows Foundation<br>មូលនិធិហ្វ្រេដហូលស៍ |
| GCF | Green Climate Fund<br>មូលនិធិអាកាសធាតុបៃតង |
| Germany | Government of Germany<br>រដ្ឋាភិបាលអាល្លឺម៉ង់ |
| GEF | Global Environment Facility<br>មូលនិធិបរិស្ថានសកល |
| GIZ | Deutsche Gesellschaft für Internationale Zusammenarbeit<br>ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ |
| Global Fund | Global Fund<br>មូលនិធិសកល |
| GPE | Global Partnership for Education<br>ភាពជាដៃគូសកលសម្រាប់ការអប់រំ |
| IFAD | International Fund for Agricultural Development<br>មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម |
| ILO | International Labor Organization<br>អង្គការពលកម្មអន្តរជាតិ |
| India | Government of India<br>រដ្ឋាភិបាលឥណ្ឌា |
| Japan | Government of Japan<br>រដ្ឋាភិបាលជប៉ុន |
| JICA | Japanese International Cooperation Agency<br>ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| KfW | Kreditanstalt fuer Wiederaufbau (Credit Institute for Reconstruction)<br>វិទ្យាស្ថានឥណទានសម្រាប់ការស្តារឡើងវិញ |
| KOICA | Korea International Cooperation Agency<br>ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ |
| New Zealand | Government of New Zealand<br>រដ្ឋាភិបាលនូវែលសេឡង់ |
| RGC | Royal Government of Cambodia<br>រាជរដ្ឋាភិបាលកម្ពុជា |
| Republic of Korea | Government of the Republic of Korea<br>រដ្ឋាភិបាលកូរ៉េ |

| | |
|---|---|
| Sida | Swedish International Development Cooperation Agency<br>ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត |
| Sweden | Government of Sweden<br>រដ្ឋាភិបាលស៊ុយអែត |
| Switzerland | Government of Switzerland<br>រដ្ឋាភិបាលស្វីស |
| Thailand | Government of Thailand<br>រដ្ឋាភិបាលថៃ |
| TICA | Thailand International Cooperation Agency<br>ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិថៃ |
| UNDP | United Nations Development Program<br>កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNEP | United Nations Environment Program<br>កម្មវិធីបរិស្ថានសហប្រជាជាតិ |
| UNESCO | United Nations Educational, Scientific and Cultural Organization<br>អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌សហប្រជាជាតិ |
| UNFPA | United Nations Population Fund<br>មូលនិធិប្រជាជនសហប្រជាជាតិ |
| UNICEF | United Nations International Children's Fund<br>មូលនិធិកុមារអន្តរជាតិសហប្រជាជាតិ |
| USAID | United States Agency for International Development<br>ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ |
| Vietnam | Government of Vietnam<br>រដ្ឋាភិបាលវៀតណាម |
| WFP | World Food Program<br>កម្មវិធីស្បៀងអាហារពិភពលោក |
| World Bank | World Bank<br>ធនាគារពិភពលោក |

# ជំពូកទី១
## សេចក្តីផ្តើម

១- គោលបំណងសំខាន់នៃ*កម្មវិធីវិនិយោគសាធារណៈ(ក.វ.ស.)៣ឆ្នាំរំកិល២០២២-២០២៤* គឺធ្វើការបង្ហាញពីទិន្នន័យគម្រោងវិនិយោគដែលមានអាទិភាពខ្ពស់របស់ក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា ដែលជាគោលនយោបាយមានចែងនៅក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ និងជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តគោលនយោបាយ ដែលមានចែងក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) ២០១៩-២០២៣។ ផ.យ.អ.ជ.២០១៩-២០២៣ ដែលបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិកាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ ត្រូវបានរៀបចំឡើងដោយមានមូលដ្ឋានពីធាតុចូលរបស់ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា។

២- *ក.វ.ស.៣ឆ្នាំរំកិល* បានដាក់បញ្ចូលគ្នា*គម្រោងកំពុងដំណើរការ* ដែលការអនុវត្តគម្រោងកំពុងបន្តនៅក្នុងដំណាក់កាលក.វ.ស. និង*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* ជាគម្រោងស្នើសុំថ្មីដែលត្រូវអនុវត្តក្នុងដំណាក់កាលក.វ.ស.។

ប្រភពទិន្នន័យសម្រាប់រៀបចំក.វ.ស. រួមមាន៖

(១) ព័ត៌មានស្តីពី*គម្រោងកំពុងដំណើរការ* ក្នុងនោះគម្រោងកំពុងដំណើរការក្នុងក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការ ត្រូវបានផ្តល់ដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងពិនិត្យកែសម្រួលដោយក្រសួងស្ថាប័នអនុវត្តគម្រោងរបស់រាជរដ្ឋាភិបាលកម្ពុជា។ និង

(២) ព័ត៌មានស្តីពី*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* ដែលក្រសួងផែនការបានទទួលពីក្រសួងស្ថាប័នទាំងអស់សម្រាប់រៀបចំ*ក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤*។

### ក- ដំណើរការនៃការងារដឹកនាំដំណើរការសុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋនិងហិរញ្ញប្បទានសហប្រតិបត្តិការ

៣- នៅពាក់កណ្តាលឆ្នាំ២០០៩ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចបង្កើត*ក្រុមការងារដឹកនាំដំណើរការសុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ* ដើម្បីពង្រឹងការងារសុខដុមនីយកម្ម ការងារផែនការ និងការអនុវត្តជាក់ស្តែង ដែលជាគោលដៅសំខាន់នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

៤- បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងធ្វើការពង្រឹងសមត្ថភាពស្ថាប័នដើម្បីភ្ជាប់ទំនាក់ទំនងនៃដំណើរការ៖

(១) កំណត់តម្រូវការជាអាទិភាពសម្រាប់វិនិយោគតាមរយៈកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលដែលរៀបចំឡើងដោយក្រសួងផែនការ។

(២) រៀបចំផែនការយុទ្ធសាស្ត្រថវិកាដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

(៣) រៀបចំទិន្នន័យនៃគម្រោងវិនិយោគមូលធនដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ និង

(៤) រៀបចំទិន្នន័យនៃគម្រោងកំពុងដំណើរការនិងការវិភាជធនធានរបស់ដៃគូអភិវឌ្ឍនានាដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

៥- ក្រុមការងារដឹកនាំដំណើរការសុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋនិងហិរញ្ញប្បទានសហប្រតិបត្តិការនេះដឹកនាំដោយក្រសួងផែនការ និងមានសមាជិកមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ក្រុមការងារបានរៀបចំកិច្ចប្រជុំជាច្រើនដងដើម្បីពិភាក្សានិងកំណត់ទិសដៅការងាររបស់ខ្លួន។ បច្ចុប្បន្ននេះ ក្របខ័ណ្ឌការងាររួមមួយសម្រាប់ការតាមដានត្រួតពិនិត្យការងាររបស់ក្រុមការងារ ត្រូវបានកំណត់ជាសូចនាករសម្រាប់ការតាមដានរួមគ្នា(JMIs) សម្រាប់សកម្មភាពនេះ។ តាមរយៈសូចនាករសម្រាប់ការតាមដានរួមគ្នា ពេលនេះ ក្រុមការងារបានធ្វើការវិភាគស្ថានភាពលើការងាររបស់ខ្លួនដើម្បីឈានទៅសម្រេចបានក្របខ័ណ្ឌលទ្ធផលដែលមានចែងនៅក្នុងជំពូកទី៦នៃផ.យ.អ.ជ. ២០១៩-២០២៣។

## ខ- វិធីសាស្ត្រសម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០២២-២០២៤

៦- សម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០២២-២០២៤ ក្រសួងផែនការបានបន្តធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីឈានទៅសម្រេចបាននូវសុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ និងដើម្បីពង្រឹងយន្តការស្ថាប័ននៃការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព។

៧- វិធីសាស្ត្រសម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០២២-២០២៤ ត្រូវបានអនុវត្តដូចការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០២១-២០២៣។ ដោយវិធីសាស្ត្រថ្មីនេះ រួមមាន ***គម្រោងកំពុងដំណើរការ*** គឺជាគម្រោងដែលកំពុងត្រូវបានអនុវត្តឬមានកិច្ចសហការនិងការសម្របសម្រួលជាមួយស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយការអនុវត្តគម្រោងទាំងនោះនឹងត្រូវបន្តនៅក្នុងកំលុងពេលនៃក.វ.ស. ៣ឆ្នាំរំកិល២០២២-២០២៤ និង ***គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ឬគម្រោងថ្មី*** ដែលនឹងត្រូវអនុវត្តក្នុង

កំលុងពេលនៃក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤។ គម្រោងកំពុងដំណើរការ គឺត្រូវបានដាក់បញ្ចូលនូវគម្រោងដែលកំពុងអនុវត្តដោយអង្គការសង្គមស៊ីវិលនានា ដោយសហការជាមួយក្រសួងស្ថាប័នតាមវិស័យពាក់ព័ន្ធ។ ព័ត៌មានសម្រាប់ការរៀបចំក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤ ត្រូវបានធ្វើការកែលម្អតាមរយៈកម្រងបញ្ជីសំណួរថ្មីដែលបានចែកចេញជាពីរផ្នែក។ **ផ្នែកទី១** គឺការប្រមូលព័ត៌មានស្ដីពី*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* និង**ផ្នែកទី២** គឺការប្រមូលព័ត៌មានស្ដីពី*គម្រោងកំពុងដំណើរការ* ដែលបញ្ជីសំណួរ ក.វ.ស.៣ឆ្នាំរំកិលថ្មី។

៨- សម្រាប់ការរៀបចំក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤ ក្រសួងផែនការបានស្នើដល់ក្រសួងស្ថាប័នឱ្យពិនិត្យមើលព័ត៌មានស្ដីពីការចំណាយជំនួយអភិវឌ្ឍផ្លូវការ ដែលដៃគូអភិវឌ្ឍរាយការណ៍នៅក្នុងប្រព័ន្ធទិន្នន័យរបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជាជារៀងរាល់ឆ្នាំ ដែលរួមមានគម្រោងកំពុងដំណើរការនិងគម្រោងអាទិភាពខ្ពស់របស់ដៃគូអភិវឌ្ឍ។ គម្រោងកំពុងដំណើរការទាំងអស់ដែលរាយការណ៍ដោយដៃគូអភិវឌ្ឍគឺជាបណ្ដាគម្រោងដែលកំពុងអនុវត្តដោយៈ (១)ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល (២)ដៃគូអភិវឌ្ឍ និង (៣)សង្គមស៊ីវិល ដោយមានការគាំទ្រផ្ដល់ថវិកាពីដៃគូអភិវឌ្ឍ។

៩- ប្រភពទិន្នន័យសំខាន់សម្រាប់ការរៀបចំក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤ គឺក្រសួងផែនការបានទទួលពីគ្រប់ក្រសួងស្ថាប័ន។ តាមរយៈការអនុវត្តជាក់ស្ដែង យើងទទួលស្គាល់ថា ទិន្នន័យស្ដីពីគម្រោងកំពុងដំណើរការដែលក្រសួងស្ថាប័នផ្ញើមកក្រសួងផែនការមានដាក់បញ្ចូលនូវគម្រោងកំពុងដំណើរការមួយចំនួន ដែលដៃគូអភិវឌ្ឍបានរាយការណ៍ជូនគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា។ ប៉ុន្តែដើម្បីធានាបាននូវការកត់ត្រាច្បាស់លាស់នូវចំនួនគម្រោងកំពុងដំណើរការដែលកំពុងអនុវត្តដោយមានកិច្ចសហការជាមួយក្រសួងស្ថាប័ននីមួយៗ និងដើម្បីជួយសម្រួលដល់ការរៀបចំទិន្នន័យគម្រោងកំពុងដំណើរការរបស់ក្រសួងស្ថាប័ន ក្រសួងផែនការបានស្នើដល់ក្រសួងស្ថាប័នឱ្យពិនិត្យបញ្ជីគម្រោង ជាពិសេសគម្រោងកំពុងដំណើរការដែលមាននៅក្នុងប្រព័ន្ធទិន្នន័យរបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា សម្រាប់ដាក់បញ្ចូលក្នុងក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤។

១០- ចំពោះ*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.(គម្រោងថ្មី)* ដែលនឹងត្រូវអនុវត្តក្នុងកំលុងឆ្នាំ២០២២-២០២៤ ក្រសួងផែនការបានផ្ដល់សេចក្ដីណែនាំនិងពន្យល់ដោយផ្ទាល់ដល់គ្រប់ក្រសួងស្ថាប័នបន្ថែមពីលើការពន្យល់តាមរយៈសិក្ខាសាលាជាតិនាពេលកន្លងមក ដើម្បីធានាថាក្នុងការស្នើសុំ*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* ក្រសួងស្ថាប័នទាំងអស់បានៈ

(១) វិភាគច្បាស់លាស់ពីសារៈសំខាន់នៃគម្រោងទាំងនោះ ក្នុងការគាំទ្រដល់គោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីឈានទៅសម្រេចបាននូវគោលនយោបាយជាអាទិភាពនៃយុទ្ធសាស្ត្រ

ចតុកោណដំណាក់កាលទី៤ ព្រមទាំងផែនការរបស់ក្រសួងស្ថាប័នដែលមានចែងនៅក្នុងផ. យ. អ. ជ. ២០១៩-២០២៣។

(២) ពិនិត្យច្បាស់លាស់ការវិភាជតាមវិស័យអាទិភាព ដែលមានចែងនៅក្នុងផ. យ. អ. ជ. ២០១៩-២០២៣។

(៣) ពិនិត្យលទ្ធផលនៃកិច្ចពិភាក្សារវាងមន្ត្រីរបស់ក្រសួងស្ថាប័ននីមួយៗជាមួយអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការរៀបចំ *ផែនការយុទ្ធសាស្ត្រថវិការ* យៈពេលវែងសម្រាប់ក្រសួងស្ថាប័នរបស់ខ្លួន។

(៤) ពិនិត្យច្បាស់លាស់ពីប្រភពធនធានជាសក្តានុពលក្នុងការផ្តល់ហិរញ្ញប្បទានដល់គម្រោងសម្រាប់អនុវត្តផ. យ. អ. ជ.។

(៥) កំណត់ *លំដាប់អាទិភាព* ចំពោះគម្រោងសម្រាប់អនុវត្តផ. យ. អ. ជ. នីមួយៗដែលក្រសួងស្ថាប័នបានផ្ញើមកក្រសួងផែនការ។ នាពេលសិក្ខាសាលាជាតិស្តីពីការផ្សព្វផ្សាយដំណើរការនៃការរៀបចំក. វ. ស. ៣ឆ្នាំរំកិល២០១១-២០១៣ និងក្នុងលិខិតជូនដំណឹងអំពីការរៀបចំក. វ. ស. ៣ឆ្នាំរំកិល ២០២២-២០២៤ ក្រសួងផែនការបានបញ្ជាក់ច្បាស់ថា៖

- អាទិភាពគម្រោងមិនអាចមានលំដាប់ដូចគ្នានៅក្នុងក្រសួងស្ថាប័នតែមួយ
- ចំពោះករណីគម្រោងអភិក្រមគ្រប់គ្រងទូទាំងវិស័យឬកម្មវិធីធំត្រូវផ្តល់ព័ត៌មានស្តីពីផ្នែកទាំងឡាយនៃគម្រោងដែលអាចទទួលបានហិរញ្ញប្បទានជាគម្រោង ព្រមទាំងគម្រោងតាមផ្នែកផ្សេងៗទៀតដែលត្រូវការនូវការកំណត់លំដាប់អាទិភាពដោយផ្អែកលើរយៈពេលនៃការអនុវត្តសកម្មភាពអភិក្រមគ្រប់គ្រងទូទាំងវិស័យឬសកម្មភាពដែលបានកំណត់របស់កម្មវិធីធំៗ
- ក្រសួងផែនការនឹងធ្វើការផ្តល់លេខគម្រោងដល់គ្រប់គម្រោងក. វ. ស. ៣ឆ្នាំរំកិលទាំងអស់ដែលថ្នាក់ដឹកនាំក្រសួងស្ថាប័នបានកំណត់អាទិភាពនិងផ្ញើមកក្រសួងផែនការ។

១១- ក្រសួងផែនការធ្វើការវិភាជថវិកាសម្រាប់ *ក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤* ដោយមានមូលដ្ឋាននៃលក្ខណវិនិច្ឆ័យដូចខាងក្រោម៖

- ការវិភាជសរុបសម្រាប់វិស័យដល់គម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ. យ. អ. ជ. ត្រូវមានសង្គតិភាពជាមួយការវិភាជតាមវិស័យដែលមានចែងនៅក្នុងផ. យ. អ. ជ. ២០១៩-២០២៣។
- អាទិភាពនៃការវិភាជថវិកាដែលមានដល់បណ្តាគម្រោងកំពុងដំណើរការ ដើម្បីបន្តការអនុវត្តនិងបញ្ចប់ការអនុវត្ត។
- ថវិកាដែលនៅសល់នឹងត្រូវធ្វើការវិភាជដល់គម្រោងសម្រាប់អនុវត្តផ. យ. អ. ជ. ដោយផ្អែកលើ៖
    - អាទិភាពនៃគម្រោងដែលកំណត់ដោយក្រសួងស្ថាប័ន

- គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ទាំងនោះសម្រាប់អនុវត្តយុទ្ធសាស្ត្រតាមវិស័យរបស់ក្រសួងស្ថាប័ន ដើម្បីអនុវត្តគោលនយោបាយអាទិភាពនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងអាទិភាពដែលមានចែងនៅក្នុងផ.យ.អ.ជ.២០១៩-២០២៣
- ព័ត៌មានដែលក្រសួងស្ថាប័នបានផ្ញើមកក្រសួងផែនការស្ដីពីស្ថានភាពសក្ដានុពលក្នុងការសន្យាផ្ដល់ហិរញ្ញប្បទានដល់គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.
- កិច្ចពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងកែសម្រួលឡើងវិញនូវការសន្យាផ្ដល់ថវិកាពីកញ្ចប់ថវិកាជាតិ និងលទ្ធផលនៃកិច្ចពិភាក្សារវាងក្រសួងស្ថាប័ននិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា សម្រាប់ក្រសួងស្ថាប័ននីមួយៗ។

១២- ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃ *ក.វ.ស. ៣ឆ្នាំរំកិល* ក្រសួងផែនការបានរៀបចំកែសម្រួលឡើងវិញនូវប្រព័ន្ធទិន្នន័យរបស់ *ក.វ.ស. ៣ឆ្នាំរំកិល* និងបញ្ចីសំណួរដាក់ក្នុងប្រព័ន្ធទិន្នន័យតាមអនឡាញសម្រាប់ឱ្យមន្ត្រីរបស់ក្រសួងស្ថាប័នទាំងអស់បំពេញព័ត៌មានគម្រោងរបស់ខ្លួននិងផ្ញើត្រឡប់មកក្រសួងផែនការវិញតាមប្រព័ន្ធទិន្នន័យតាមអនឡាញនេះ(pip.mop.gov.kh)។

១៣- នៅក្នុង *ក.វ.ស. ៣ឆ្នាំរំកិល* ឆ្នាំមុនៗ (មុន *ក.វ.ស. ៣ឆ្នាំរំកិល២០១១-២០១៣*) ក្រសួងផែនការបានរៀបចំរបាយការណ៍វាយតម្លៃលើស្ថានភាពនៃការអនុវត្តគម្រោង *ក.វ.ស. ៣ឆ្នាំរំកិល* ។ ប៉ុន្តែបច្ចុប្បន្ននេះគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជាបានរៀបចំរបាយការណ៍ស្ដីពីប្រសិទ្ធភាពជំនួយ ដែលរួមមានការវិភាគលើការបន្ស៊ីធនធានដែលបានផ្ដល់ជាមួយនឹងការវិភាជតាមវិស័យមានចែងនៅក្នុង *ផ.យ.អ.ជ.*។ ដូច្នេះ *ក.វ.ស. ៣ឆ្នាំរំកិល២០២២-២០២៤* ក៏មិនដាក់បញ្ចូលនូវរបាយការណ៍វាយតម្លៃលើស្ថានភាពនៃការអនុវត្តគម្រោង *ក.វ.ស. ៣ឆ្នាំរំកិល* ដូចនៅឆ្នាំមុនទៀតដែរ។

១៤- បន្ទាប់ពីសេចក្ដីផ្ដើមនៃ *ក.វ.ស. ៣ឆ្នាំរំកិល២០២២-២០២៤* នឹងមានបង្ហាញអំពីព័ត៌មានស្ដីពីទស្សនវិស័យសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០២២-២០២៤ ក្នុងជំពូកទី២។ ជំពូកទី៣បង្ហាញអំពីព័ត៌មានស្ដីពី *ក.វ.ស. ៣ឆ្នាំរំកិល២០២២-២០២៤* និងជំពូកទី៤បង្ហាញអំពីសេចក្ដីសន្និដ្ឋាន។

# ជំពូកទី២

## ទស្សនវិស័យសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០២២-២០២៤

### ក- ស្ថានភាពទូទៅនៃកំណើនផលិតផលក្នុងស្រុកសរុប២០២២-២០២៤

១៥- តាមការព្យាករ សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០២១ត្រូវបានព្យាករថានឹងងើបឡើងវិញ ហើយរំពឹងថានឹងសម្រេចបានកំណើនក្នុងរង្វង់២,៤% ដែលធ្វើឱ្យផ.ស.ស.ស្ថិតក្នុងរង្វង់១១៥ ២១៣ប៊ីលានរៀល (២៨ ៣៤៣លានដុល្លារអាម៉េរិក) ស្របពេលដែលផ.ស.ស.សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់១ ៧៣០ដុល្លារអាម៉េរិក បើប្រៀបធៀបនឹង១ ៦៥៣ដុល្លារអាម៉េរិកក្នុងឆ្នាំ២០២០។ កំណើនសេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំ២០២១ត្រូវបានទ្រទ្រង់ដោយវិស័យឧស្សាហកម្មដែលត្រូវបានព្យាករថា នឹងងើបឡើងវិញក្នុងអត្រាកំណើន៥,៧%ក្នុងឆ្នាំ២០២១ពីកំណើនអវិជ្ជមានក្នុងអត្រា-១,២%ក្នុងឆ្នាំ២០២០ ដោយសារការរំពឹងទុកនូវការងើបឡើងវិញក្នុងកម្រិតទាបនៃអនុវិស័យកាត់ដេរនិងអនុវិស័យសំណង់ ខណៈអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរត្រូវបានរំពឹងថានៅរក្សាបានកំណើនល្អប្រសើរ វិស័យសេវាកម្មដែលត្រូវបានព្យាករថានឹងមានកំណើនក្នុងអត្រាទាប០,៣%ក្នុងឆ្នាំ២០២១ បើប្រៀបធៀបនឹងកំណើនអវិជ្ជមានក្នុងអត្រា-៦,៧%ក្នុងឆ្នាំ២០២០ ដោយសារការរំពឹងទុកនៃការងើបឡើងវិញក្នុងកម្រិតទាបនៃសកម្មភាពសេដ្ឋកិច្ច ជាពិសេសក្នុងវិស័យទេសចរណ៍និងការប្រើប្រាស់ក្នុងស្រុក បន្ទាប់ពីវិបត្តិកូវីដ-១៩ វិស័យកសិកម្មដែលត្រូវបានព្យាករថានឹងកើនឡើងក្នុងអត្រា១,៤%ក្នុងឆ្នាំ២០២១ពីកំណើន០,៥%ក្នុងឆ្នាំ២០២០ ដោយសារការកើនឡើងនៃអនុវិស័យដំណាំ អនុវិស័យចិញ្ចឹមសត្វ និងអនុវិស័យនេសាទ។ អតិផរណាត្រូវបានប៉ាន់ស្មានថាស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានក្នុងអត្រា៣,៤%ក្នុងឆ្នាំ២០២១ ដោយសារការរំពឹងទុកការកើនឡើងថ្លៃប្រេងលើទីផ្សារអន្តរជាតិ បន្ទាប់ពីការធ្លាក់ចុះយ៉ាងគំហុកក្នុងឆ្នាំ២០២០។ អត្រាប្តូរប្រាក់រៀល ត្រូវបានប៉ាន់ស្មានថានឹងនៅតែបន្តស្ថិតក្នុងរង្វង់៤ ០៦៥រៀលក្នុង១ដុល្លារអាម៉េរិកក្នុងឆ្នាំ២០២១ ដោយសារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជំនឿទុកចិត្តពីសំណាក់ប្រជាជនលើការប្រើប្រាស់ប្រាក់រៀល តាមរយៈការអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជានិងការបន្តពង្រឹងគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុ។ ជាមួយគ្នានេះដែរ អត្រាប្តូរប្រាក់នៅបន្តមានស្ថិរភាពក្នុងតម្លៃប្រមាណ៤ ០៨០រៀលក្នុង១ដុល្លារអាម៉េរិក នៅក្នុងឆ្នាំ២០២០នេះ។ ការព្យាករអំពីសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗសម្រាប់ឆ្នាំ២០២១-២០២៤ ត្រូវបានបង្ហាញក្នុងតារាងទី១។

១៦- រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តខ្ពស់ក្នុងការកាត់បន្ថយគម្លាតចំណូលនិងចំណាយ តាមរយៈការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ ដើម្បីធានាបានដល់ការបង្កើនប្រសិទ្ធភាព និងគណនេយ្យភាពនៃការវិភាជថវិកានិងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ។ ការអនុវត្តថវិកាបានបង្ហាញឱ្យ

ឃើញនូវការកែទម្រង់ស៊ីជម្រៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងនោះ រួមមានការដំឡើងបៀវត្សរ៍ជូនមន្ត្រីរាជការ យោធិន នគរបាលជាតិ និងនិវត្តជន ជាពិសេស ជូនគ្រូបង្រៀននិងគ្រូពេទ្យ ទន្ទឹមនឹងធ្វើការកែទម្រង់ប្រព័ន្ធបៀវត្សរ៍និងប្រព័ន្ធរដ្ឋបាលសាធារណៈ ហើយប្រការដែលសំខាន់បំផុត គឺការធានាបាននូវការបើកប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការបានទាន់ពេលវេលា២ដងនៃខែនីមួយៗ។

**តារាងទី១ : ការព្យាករអំពីសូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច**

| សូចនាករសេដ្ឋកិច្ច | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|
| ផ.ស.ស. (ថ្លៃបច្ចុប្បន្ន-គិតជាលានដុល្លារអាមេរិក) | ២៨ ៣៨៣ | ៣០ ៥៤៤ | ៣៣ ២១០ | ៣៦ ៤០៣ |
| ផ.ស.ស. សម្រាប់ប្រជាជនម្នាក់ (ដុល្លារអាមេរិក) | ១ ៧៣០ | ១ ៨៤២ | ១ ៩៧៩ | ២ ១៤៣ |
| **អត្រាកំណើនពិតនៃផ.ស.ស. (%)** | **២,៤** | **៤,៨** | **៦,២** | **៦,៩** |
| | | | | |
| **អតិផរណា (ការប្រែប្រួលជាមធ្យមប្រចាំឆ្នាំ-គិតជាភាគរយ)** | **៣,៤** | **២,៨** | **៣,០** | **៣,០** |
| | | | | |
| **ការវិនិយោគសរុប (%ផ.ស.ស.)** | **៣៥,៨** | **៣៥,៦** | **៣៥,៩** | **៣៣,៧** |
| ការវិនិយោគសាធារណៈ (%ផ.ស.ស.) | ១០,៤ | ៩,៧ | ៩,៨ | ៨,២ |
| ការវិនិយោគឯកជន (%ផ.ស.ស.) | ២៥,៤ | ២៥,៩ | ២៦,១ | ២៥,៦ |
| | | | | |
| **ចំណូលថវិកាសរុប (%ផ.ស.ស.)** | **១៩,២** | **១៩,៦** | **២០,២** | **២០,៨** |
| **ចំណាយថវិកាសរុប (%ផ.ស.ស.)** | **៣០,៥** | **២៨,៣** | **២៩,១** | **២៥,៨** |

ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ខែសីហា ឆ្នាំ២០២១)

១៧- រាជរដ្ឋាភិបាលកម្ពុជាមានផែនការច្បាស់លាស់សម្រាប់ការរៀបចំ *ផ.យ.អ.ជ. ២០១៩-២០២៣* គឺវិស័យហេដ្ឋារចនាសម្ព័ន្ធ ថាមពល ការអប់រំនិងការបណ្តុះបណ្តាលជំនាញ ប្រព័ន្ធដឹកជញ្ជូន និងភស្តុភារ ព្រមទាំងប្រព័ន្ធបច្ចេកវិទ្យានឹងត្រូវបានពង្រឹងនិងពង្រីកបន្ថែម ដែលជាជំនួយដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ដូចជាសហគ្រាសធុនតូចនិងមធ្យមកែច្នៃចំណីអាហារនិងឧស្សាហកម្មរ៉ែ។

**ខ- អត្រាកំណើនផ.ស.ស.ពិត(ថ្លៃថេរឆ្នាំ២០០០)តាមវិស័យ**

១៨- ការព្យាករអំពីអត្រាកំណើនផ.ស.ស.ដោយសកម្មភាពសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០២១-២០២៤ ដូចបានបង្ហាញក្នុងតារាងទី២។

**តារាងទី២ : អត្រាកំណើនផ.ស.ស.(ថ្លៃថេរឆ្នាំ២០០០)តាមវិស័យ**

| | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|
| **វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **១,៤%** | **១,១%** | **១,២%** | **១,២%** |
| ដំណាំ | ១,៩% | ១,៤% | ១,៥% | ១,៥% |
| បសុសត្វនិងបសុបក្សី | ០,៨% | ០,៩% | ១,០% | ១,១% |
| ជលផល | ១,១% | ០,៩% | ១,១% | ១,២% |
| ផលព្រៃឈើ | -១,៤% | -១,៦% | -១,៦% | -១,៧% |
| **វិស័យឧស្សាហកម្ម** | **៥,៧%** | **៧,៧%** | **៩,២%** | **១០,១%** |
| កាត់ដេរ | ៤,៦% | ៦,៨% | ៧,៩% | ៨,៣% |
| សំណង់ | ១,៤% | ៥,០% | ៨,០% | ១០,៣% |
| ឧស្សាហកម្មផ្សេងទៀត | ១៣,៥% | ១២,៥% | ១២,៦% | ១២,៧% |
| **វិស័យសេវា** | **០,៣%** | **៤,១%** | **៥,៦%** | **៦,២%** |
| សណ្ឋាគារនិងភោជនីយដ្ឋាន | -៣១,២% | ១,៥% | ៤,១% | ៥,៥% |
| ពាណិជ្ជកម្ម | ២,៩% | ៥,០% | ៦,៧% | ៦,៩% |
| ដឹកជញ្ជូននិងគមនាគមន៍ | ៥,២% | ៦,៤% | ៧,១% | ៧,៥% |
| អចលនទ្រព្យ | ០,៦% | ២,៦% | ៥,២% | ៦,៤% |
| សេវាកម្មផ្សេងទៀត | ១,៩% | ២,០% | ៣,៤% | ៤,១% |
| **ពន្ធដកឧបត្ថម្ភធន** | **-១,០%** | **២,២%** | **៤,៥%** | **៥,៥%** |
| **ផលិតផលក្នុងស្រុកសរុប** | **២,៤%** | **៤,៨%** | **៦,២%** | **៦,៩%** |

ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ខែសីហា ឆ្នាំ២០២១)

## គ- ការវិនិយោគដែលចាំបាច់ដើម្បីសម្រេចបាននូវកំណើនផ.ស.ស.ដែលបានគ្រោងទុក

១៩- ប្រភពផ្តល់ហិរញ្ញប្បទានដល់វិនិយោគសរុបចំនួន១៤២ ៥៨៣,៩ប៊ីលានរៀល (៣៥ ០៧៦,០លានដុល្លារអាមេរិក) ក្នុងកំលុងពេល*ក.វ.ស. ៣ឆ្នាំរំកិល២០២២-២០២៤*(មានបង្ហាញនៅក្នុងតារាងទី៣)៖

- វិនិយោគមូលធនរបស់វិស័យឯកជននឹងមានប្រមាណ១០៥ ១៧៧,៨ប៊ីលានរៀល (២៥ ៨៧៤,០លានដុល្លារអាមេរិក) សមមូលនឹង៧៣,៨%នៃវិនិយោគមូលធនសរុប
- វិនិយោគមូលធនវិស័យសាធារណៈនឹងមានប្រមាណ៣៧ ៤០២,១ប៊ីលានរៀល (៩ ២០១,០លានដុល្លារអាមេរិក) សមមូលនឹង២៦,២%នៃវិនិយោគមូលធនសរុប។

២០- ប្រភពធនធានសម្រាប់តម្រូវការវិនិយោគពីក្នុងស្រុកនិងពីក្រៅប្រទេសសម្រាប់ផ្តល់ហិរញ្ញប្បទានដល់តម្រូវការវិនិយោគមូលធនវិស័យសាធារណៈសរុប៣៧ ៤០២,១ប៊ីលានរៀល (៩ ២០១,០លានដុល្លារអាមេរិក) ក្នុងកំលុងពេល*ក.វ.ស. ៣ឆ្នាំរំកិល២០២២-២០២៤*៖

- ១៦ ២២៧,៥ប៊ីលានរៀល (៣ ៩៩២,០លានដុល្លារអាម៉េរិក) សមមូលនឹង៤៣,៤% នៃវិនិយោគមូលធនសរុបនឹងត្រូវបានទទួលពីប្រភពក្នុងស្រុក
- ២១ ១៧៤,៦ប៊ីលានរៀល(៥ ២០៩,០លានដុល្លារអាម៉េរិក) សមមូលនឹង៥៦,៦% នៃវិនិយោគមូលធនសរុបនឹងត្រូវបានទទួលពីប្រភពក្រៅប្រទេស។

**តារាងទី៣ : ការវិនិយោគមូលធនចាំបាច់ ដើម្បីសម្រេចបានកំណើនផ.ស.ស.ដែលបានគ្រោងទុក និងធនធានដែលអាចមានសម្រាប់ផ្ដល់ហិរញ្ញប្បទានដល់ការវិនិយោគចាំបាច់**

(គិតជាលានដុល្លារអាម៉េរិក)

| ប្រភពហិរញ្ញប្បទាន | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប ២០២២-២០២៤ |
|---|---|---|---|---|---|
| **វិនិយោគមូលធនសរុប** | **១០ ១៥៨** | **១០ ៨៦៧** | **១១ ៩២៥** | **១២ ២៨៣** | **៣៥ ០៧៦** |
| • **វិនិយោគសាធារណៈ** | **២ ៩៥៣** | **២ ៩៦៨** | **៣ ២៦២** | **២ ៩៧១** | **៩ ២០១** |
| ➢ ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ១ ៣២៨ | ១ ២៩៩ | ១ ៤២៩ | ១ ២៦៤ | ៣ ៩៩២ |
| ➢ ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស | ១ ៦២៥ | ១ ៦៦៩ | ១ ៨៣៤ | ១ ៧០៧ | ៥ ២០៩ |
| • **វិនិយោគឯកជន** | **៧ ២០៥** | **៧ ៨៩៩** | **៨ ៦៦៤** | **៩ ៣១២** | **២៥ ៨៧៤** |
| ➢ ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ៣ ៧៥៣ | ៤ ០៤១ | ៤ ៣១៩ | ៤ ៣៩៦ | ១២ ៧៥៥ |
| ➢ ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស | ៣ ៤៥២ | ៣ ៨៥៨ | ៤ ៣៤៥ | ៤ ៩១៦ | ១៣ ១១៩ |
| **វិនិយោគមូលធនសរុប** | **១០ ១៥៨** | **១០ ៨៦៧** | **១១ ៩២៥** | **១២ ២៨៣** | **៣៥ ០៧៦** |
| • វិនិយោគសាធារណៈ | ២ ៩៥៣ | ២ ៩៦៨ | ៣ ២៦២ | ២ ៩៧១ | ៩ ២០១ |
| • វិនិយោគឯកជន | ៧ ២០៥ | ៧ ៨៩៩ | ៨ ៦៦៤ | ៩ ៣១២ | ២៥ ៨៧៤ |

ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ខែសីហា ឆ្នាំ២០២១)

សម្គាល់÷ អត្រាប្ដូរប្រាក់១ដុល្លារអាម៉េរិកស្មើនឹង៤ ០៦៥រៀល

២១- ការបែងចែកលម្អិតនៃការវិនិយោគចាំបាច់ដើម្បីសម្រេចបាននូវកំណើនផ.ស.ស.សរុប ដែលបានគ្រោងទុកតាមរយៈវិស័យសេដ្ឋកិច្ច ត្រូវបានបង្ហាញក្នុងតារាងទី៤។ ដើម្បីសម្រេចបានអត្រាកំណើនផ.ស.ស. សរុប ដែលបានគ្រោងទុកតាមវិស័យ ការវិនិយោគក្នុងក្រុមវិស័យសំខាន់ៗ រួមមានដូចខាងក្រោម៖

- វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវការទុនវិនិយោគចំនួន១៧ ៤៦៧,៣ប៊ីលានរៀល (៤ ២៩៧,០លានដុល្លារអាម៉េរិក) ដែលផ្តោតជាសំខាន់លើដំណាំស្រូវជាពិសេស ដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់ការបង្កើនការនាំអង្ករទៅទីផ្សារអន្តរជាតិសម្រាប់រយៈពេលក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤
- វិស័យឧស្សាហកម្មទូទៅ រួមមានការរុករករ៉ែ កម្មន្តសាល អគ្គិសនី ឧស្ម័ន ទឹក និងសំណង់ នឹងត្រូវការទុនវិនិយោគចំនួន៧១ ៣៧៣,៣ប៊ីលានរៀល(១៧ ៥៥៨,០លានដុល្លារអាម៉េរិក) សម្រាប់រយៈពេលក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤។ នៅក្នុងក្រុមនេះ អនុវិស័យកម្មន្តសាល នឹងត្រូវការចំណែកធំជាងគេនៃការវិនិយោគ គឺមានចំនួនប្រមាណ២៤ ៤៦៣,២ប៊ីលានរៀល (៦ ០១៨,០លានដុល្លារអាម៉េរិក) និងអនុវិស័យសំណង់ ត្រូវការចំណែកធំនៃការវិនិយោគ គឺមានចំនួន៣៧ ៦៨២,២ប៊ីលានរៀល(៩ ២៧០,០លានដុល្លារអាម៉េរិក) ហើយអនុវិស័យអគ្គិសនី ឧស្ម័ន និងទឹកត្រូវការទុនវិនិយោគចំនួនប្រមាណ៨ ០៦៥,០ប៊ីលានរៀល(១ ៩៨៤,០លានដុល្លារអាម៉េរិក)
- វិស័យសេវា រួមមានពាណិជ្ជកម្ម សណ្ឋាគារ និងភោជនីយដ្ឋាន(ទេសចរណ៍) ដឹកជញ្ជូននិងគមនាគមន៍ ហិរញ្ញវត្ថុ រដ្ឋបាលសាធារណៈ និងអចលនទ្រព្យត្រូវការទុនវិនិយោគចំនួន៥៣ ៧៤៣,៤ប៊ីលានរៀល(១៣ ២២១,០លានដុល្លារអាម៉េរិក)។

**តារាងទី៤ : ការប៉ាន់ស្មានត្រូវការវិនិយោគមូលធនប្រចាំឆ្នាំតាមវិស័យ (តម្លៃបច្ចុប្បន្ន)**

(គិតជាលានដុល្លារអាម៉េរិក)

| | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប ២០២២-២០២៤ |
|---|---|---|---|---|---|
| **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **១ ២៦០** | **១ ៣៤១** | **១ ៤៥២** | **១ ៥០៣** | **៤ ២៩៧** |
| ដំណាំ | ១ ០៤៣ | ១ ១២១ | ១ ២២៥ | ១ ២៩២ | ៣ ៦៣៩ |
| បសុសត្វនិងបសុបក្សី | ៦៩ | ៧០ | ៧៧ | ៧២ | ២១៩ |
| ជលផល | ៩៧ | ៩៨ | ១០៤ | ៩៦ | ២៩៨ |
| ផលព្រៃឈើ | ៥១ | ៥២ | ៤៥ | ៤៣ | ១៤០ |
| **ឧស្សាហកម្ម** | **៥ ០១៣** | **៥ ៣៧២** | **៥ ៩១៧** | **៦ ២៦៩** | **១៧ ៥៥៨** |
| រ៉ែ | ៧៩ | ៩១ | ៧៦ | ១២០ | ២៨៦ |
| កម្មន្តសាល | ១ ៦១២ | ១ ៧៨៩ | ១ ៩៩៦ | ២ ២៣៣ | ៦ ០១៨ |
| អាហារនិងភេសជ្ជៈនិងថ្នាំជក់ | ១១៤ | ១២៧ | ១៤១ | ១៥៨ | ៤២៦ |

| | ២០២១ | ២០២២ | ២០២៣ | ២០២៤ | សរុប ២០២២-២០២៤ |
|---|---|---|---|---|---|
| វាយនភណ្ឌ សម្លៀកបំពាក់ និង ស្បែកជើង | ៨០៩ | ៨៩៤ | ៩៩២ | ១ ១០៥ | ២ ៩៩១ |
| ឈើ ក្រដាស និងការបោះពុម្ព | ៧៥ | ៨២ | ៩១ | ១០១ | ២៧៤ |
| កម្មន្តសាលកៅស៊ូ | ១៤៦ | ១៦៣ | ១៨៣ | ២០៦ | ៥៥១ |
| កម្មន្តសាលផ្សេងៗទៀត | ៤៦៩ | ៥២៤ | ៥៨៨ | ៦៦៣ | ១ ៧៧៦ |
| អគ្គិសនី ឧស្ម័ន និងទឹក | ៦១៤ | ៦២៩ | ៦៩៤ | ៦៦១ | ១ ៩៨៤ |
| សំណង់ | ២ ៧០៨ | ២ ៨៦៤ | ៣ ១៥២ | ៣ ២៥៥ | ៩ ២៧០ |
| **សេវា** | **៣ ៨៨៥** | **៤ ១៥៤** | **៤ ៥៥៧** | **៤ ៥១១** | **១៣ ២២១** |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ៦៤៧ | ៧០៤ | ៧៧០ | ៨៤៥ | ២ ៣២០ |
| ពាណិជ្ជកម្ម | ៥៨៤ | ៦០៨ | ៦៥២ | ៧២១ | ១ ៩៨១ |
| ដឹកជញ្ជូននិងគមនាគមន៍ | ៩៩៦ | ១ ០៩៤ | ១ ២០៩ | ១ ៣៣៥ | ៣ ៦៣៨ |
| អចលនវត្ថុនិងធុរកិច្ច | ៤២៨ | ៤៧៥ | ៥២៥ | ៥៧៩ | ១ ៥៧៩ |
| ហិរញ្ញវត្ថុ | ១១៨ | ១៣០ | ១៤៤ | ១៦០ | ៤៣៤ |
| រដ្ឋបាលសាធារណៈ | ៨៣០ | ៨៣៥ | ៩១៨ | ៨៣៧ | ២ ៥៨៩ |
| សេវាផ្សេងៗទៀត | ២៨២ | ៣០៨ | ៣៣៨ | ៣៤ | ៦៨០ |
| **សរុប** | **១០១៥៨** | **១០ ៨៦៧** | **១១ ៩២៦** | **១២ ២៨៣** | **៣៥ ០៧៦** |

ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ខែសីហា ឆ្នាំ២០២១)

## ឃ- ចំណូលនិងចំណាយថវិកា២០២២-២០២៤

២២- ក្នុងកិច្ចខិតខំប្រឹងប្រែងប្រមូលចំណូល រាជរដ្ឋាភិបាលពុំមានគោលការណ៍បង្កើតបន្ទុកពន្ធថ្មីឬដំឡើងពន្ធបន្ថែមដល់ប្រជាជននិងធុរជននោះទេ ពោលគឺ រាជរដ្ឋាភិបាលបានផ្តោតលើការពង្រឹងការអនុវត្តគោលនយោបាយនិងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាលនិងវិធានការគោលនយោបាយ ទាំងសម្រាប់រយៈពេលខ្លី មធ្យម និងវែង ជាពិសេស ការលើកកម្ពស់វប្បធម៌បង់ពន្ធ ការបង្ក្រាបអំពើរត់ពន្ធ និងការគេចពន្ធគ្រប់រូបភាពឱ្យដល់ឫសគល់ ព្រមទាំងការកែលម្អអភិបាលកិច្ចក្នុងការប្រមូលចំណូល ទាំងក្នុងផ្នែកគយ ទាំងក្នុងផ្នែកពន្ធដារ ព្រមទាំងផ្នែកមិនមែនសារពើពន្ធ។ ជាមួយនឹងវិធានការទាំងនេះ ចំណូលក្នុងស្រុកសរុបរបស់រាជរដ្ឋាភិបាលសម្រេចបានប្រមាណ២១,៨%នៃផ.ស.ស.ក្នុងឆ្នាំ២០២០ និងត្រូវបានប៉ាន់ស្មានថានឹងថមថយបន្តិចមកត្រឹមប្រមាណ១៩,២%នៃផ.ស.ស.សម្រាប់ឆ្នាំ២០២១ ដោយសារផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩។

២៣- រាជរដ្ឋាភិបាលបាននិងកំពុងបន្តការអនុវត្តគោលនយោបាយជំរុញកំណើននិងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច សង្គមកិច្ច ជាមួយនឹងការខិតខំប្រឹងប្រែងធានាឱ្យបាននូវប្រសិទ្ធផលនិងប្រសិទ្ធភាពចំណាយ ជាពិសេស ការចំណាយសម្រាប់កម្មវិធីកាត់បន្ថយភាពក្រីក្រនិងការផ្តោតសំខាន់លើវិស័យអាទិភាពនានា ដូចជាវិស័យអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ វិស័យសុខាភិបាល វិស័យកសិកម្ម ក៏ដូចជាការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា។ ក្នុងន័យនេះ ចំណាយថវិកាសរុបក្នុងឆ្នាំ២០២១ត្រូវបានប៉ាន់ស្មានក្នុងរង្វង់៣០,៥%នៃផ.ស.ស. គឺកើនឡើង៣,០% ធៀបនឹងច្បាប់ឆ្នាំ២០២០។

២៤- ជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននិងកំពុងអនុវត្តយន្តការចំនួន២ គឺក្របខ័ណ្ឌចំណូលចំណាយរយៈពេលមធ្យម(អភិក្រមពីលើចុះក្រោម) និងផែនការយុទ្ធសាស្ត្រថវិកា(អភិក្រមពីក្រោមទៅលើ) ដើម្បីផ្តល់ជាធាតុចូលក្នុងការរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ។ ទីមួយគឺ *ក្របខ័ណ្ឌចំណាយសម្រាប់រយៈពេលមធ្យម* ដែលព្យាករពីតួលេខចំណាយចរន្តសម្រាប់រយៈពេល៣ឆ្នាំខាងមុខ។ ការព្យាករនេះនឹងត្រូវធ្វើបច្ចុប្បន្នកម្មរៀងរាល់ឆ្នាំ។ ការព្យាករផ្អែកលើការវិភាគម៉ាក្រូសេដ្ឋកិច្ចពីលើចុះក្រោម ដោយមើលលើការអនុវត្តនៃសេដ្ឋកិច្ចគោលនយោបាយអាទិភាពនិងព័ត៌មានបានពីស្ថាប័ននានារបស់រាជរដ្ឋាភិបាល។ ទីពីរគឺ *ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃថវិកាសម្រាប់រយៈពេល៣ឆ្នាំ* ដែលអនុវត្តតាមអភិក្រមពីក្រោមទៅលើ។ ធាតុចូលសម្រាប់យកមកប្រើប្រាស់ក្នុងការវិភាគនេះផ្អែកលើព័ត៌មានដែលប្រមូលបានពីការផ្លាស់ប្តូរយោបល់រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងស្ថាប័ននានារបស់រាជរដ្ឋាភិបាល និងព័ត៌មានស្តីពីចំណាយនិងតម្រូវការរយៈពេល៣ឆ្នាំទៅមុខនៃស្ថាប័នទាំងនោះ។ ក្នុងការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តពង្រឹងភាពផ្សារភ្ជាប់គ្នានៃដំណើរការទាំងពីរដើម្បីកែលម្អការរៀបចំថវិកាប្រចាំឆ្នាំ។

**ខ- ចំណុចដៅនៃការកៀរគរធនធានសម្រាប់ការវិនិយោគរបស់វិស័យសាធារណៈឆ្នាំ២០២២-២០២៤**

២៥- រាជរដ្ឋាភិបាលបានកំណត់ចំណុចដៅនៃតម្រូវការវិនិយោគរបស់វិស័យសាធារណៈដែលអាចមានតម្លៃប្រមាណ៩៥ ៥២៧,៥ប៊ីលានរៀល(២៣ ៥០០លានដុល្លារអាមេរិក) ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៦នៃរដ្ឋសភា។ សម្រាប់ក.វ.ស. ៣ឆ្នាំរំកិល២០២២-២០២៤ តម្រូវការវិនិយោគមូលធនសម្រាប់វិស័យសាធារណៈមានប្រមាណ៣៧ ៤០២,១ប៊ីលានរៀល (៩ ២០១លានដុល្លារអាមេរិក)។

**តារាងទី៥: ចំណុចដៅនៃការកៀរគរធនធានសម្រាប់វិនិយោគរបស់វិស័យសាធារណៈ ឆ្នាំ២០២២-២០២៤**

| តម្រូវការវិនិយោគវិស័យសាធារណៈ | ២០២២-២០២៤ | |
|---|---|---|
| | ប៊ីលានរៀល | លានដុល្លារអាម៉េរិក |
| វិនិយោគមូលធនរបស់វិស័យសាធារណៈ(ការព្យាករម៉ាក្រូសេដ្ឋកិច្ច) | ៣៧ ៤០២,១ | ៩ ២០១,០ |
| **សរុប** | **៣៧ ៤០២,១** | **៩ ២០១,០** |

ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងផែនការ

២៦- សម្រាប់*ក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤* គឺត្រូវការថវិកាសរុបប្រមាណ៣៧ ៤០២,១ប៊ីលានរៀល(៩ ២០១,០លានដុល្លារអាម៉េរិក)ឬប្រមាណ១២ ៤៦៧,៤ប៊ីលានរៀល(៣ ០៦៧,០លានដុល្លារអាម៉េរិក)ក្នុងមួយឆ្នាំ។ បរិមាណថវិកាសរុបសម្រាប់អនុវត្ត*ក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤* គឺត្រូវការថវិកាសរុបប្រមាណ៣៧ ៤០២,១ប៊ីលានរៀល(៩ ២០១,០លានដុល្លារអាម៉េរិក)ដែលក្នុងនោះហិរញ្ញប្បទានក្នុងស្រុកដោយរាជរដ្ឋាភិបាលមាន១៦ ២២៧,៥ប៊ីលានរៀល(៣ ៩៩២,០លានដុល្លារអាម៉េរិក) និងចំណែកដែលនៅសល់២១ ១៧៤,៦ប៊ីលានរៀល(៥ ២០៩,០លានដុល្លារអាម៉េរិក) ឬប្រមាណ៧ ០៥៨,២ប៊ីលានរៀល(១ ៧៣៦,៣លានដុល្លារអាម៉េរិក)ក្នុងមួយឆ្នាំ អាចត្រូវបានធ្វើហិរញ្ញប្បទានពីប្រភពដូចខាងក្រោម៖

- ហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍក្រៅប្រទេស(ភាគច្រើនពីដៃគូអភិវឌ្ឍទ្វេភាគី ពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាល)
- កម្ចីសម្បទានពីដៃគូអភិវឌ្ឍក្រៅប្រទេស(ភាគច្រើនពីស្ថាប័នហិរញ្ញវត្ថុពហុភាគីនិងទ្វេភាគី)
- ចំណូលថ្មីៗដែលអាចបានមកពីការអភិវឌ្ឍឧស្សាហកម្មអាជីវកម្មរ៉ែ។

២៧- រាជរដ្ឋាភិបាលកម្ពុជាមានជំនឿជឿជាក់ថា តម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ ដែលមានប្រមាណ៣៧ ៤០២,១ប៊ីលានរៀល(៩ ២០១,០លានដុល្លារអាម៉េរិក)ឬប្រមាណ១២ ៤៦៧,៤ប៊ីលានរៀល(៣ ០៦៧,០លានដុល្លារអាម៉េរិក)ក្នុងមួយឆ្នាំ អាចនឹងទទួលបានពីការបន្តគាំទ្រពីដៃគូអភិវឌ្ឍនិងពីចំណូលបន្ថែមថ្មីពីប្រេង ឧស្ម័ន និងធនធានរ៉ែ នៅពេលដែលអាជីវកម្មនេះត្រូវបានដំណើរការជាលក្ខណៈពាណិជ្ជកម្ម។ ក៏ប៉ុន្តែការកៀរគរហិរញ្ញប្បទានបន្ថែមពីដៃគូ ដូចជាមិនបានបង្ហាញពីភាពងាយស្រួលឡើយ ដោយសារដៃគូអភិវឌ្ឍភាគច្រើនបានសន្យាផ្ដល់រួចមកហើយនិងដើម្បីសម្រេចបានហិរញ្ញប្បទានគ្រប់ចំនួន គឺត្រូវខិតខំស្វែងរកបន្ថែមទៀតនូវដៃគូអភិវឌ្ឍថ្មីផ្សេងៗទៀត។ សម្រាប់រាជរដ្ឋាភិបាល គឺត្រូវពិនិត្យឱ្យច្បាស់លាស់នូវកំណែទម្រង់សេដ្ឋកិច្ច ដូចជាការបង្កើនទិន្នផលស្រូវនិងការនាំចេញ និងការធ្វើពិពិធកម្មដំណាំផ្សេងៗក្រៅពីដំណាំស្រូវ ជាពិសេស សម្រាប់អនាគត ត្រូវគ្រប់គ្រងចំណូលទទួលបានពីអាជីវកម្មរ៉ែ ដីសម្បទាននិងចំណូលពន្ធ។

២៨- ការវិភាជតាមវិស័យនិងអនុវិស័យនៃតម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ សម្រាប់ឆ្នាំ ២០២២-២០២៤ នៅក្នុងតារាងទី៦ខាងក្រោម គឺមានមូលដ្ឋានពីការវិភាជតាមវិស័យនិងអនុវិស័យ ចែង នៅក្នុងផ.យ.អ.ជ.២០១៩-២០២៣។

**តារាងទី៦ : ការវិភាជតាមវិស័យនិងអនុវិស័យសម្រាប់តម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ ដោយមានមូលដ្ឋានពីការវិភាជតាមវិស័យនិងអនុវិស័យចែងនៅក្នុងផ.យ.អ.ជ.២០១៩-២០២៣**

| វិស័យ | ភាគរយ | បរិមាណវិភាជន៍ ២០២២-២០២៤ | |
|---|---|---|---|
| | | ប៊ីលានរៀល | លានដុល្លារអាមេរិក |
| **វិស័យសង្គមកិច្ច** | | | |
| អប់រំ : ក្នុងនោះការអប់រំមូលដ្ឋាន៦០% | ១០ | ៣ ៧៤០,២ | ៩២០,១ |
| បច្ចេកទេសនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ៨ | ២ ៩៩២,២ | ៧ ៣៦,១ |
| សុខាភិបាល | ១០ | ៣ ៧៤០,២ | ៩២០,១ |
| កម្មវិធីគាំពារសង្គម/ការកាត់បន្ថយភាពក្រីក្រ | ៤ | ១ ៤៩៦,១ | ៣៦៨,០ |
| **សរុប** | **៣២** | **១១ ៩៦៨,៧** | **២ ៩៤៤,៣** |
| **វិស័យសេដ្ឋកិច្ច** | | | |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី | ៤ | ១ ៤៩៦,១ | ៣៦៨,០ |
| ដំណាំតាមរដូវ : ស្រូវនិងដំណាំផ្សេងៗ | ៤ | ១ ៤៩៦,១ | ៣៦៨,០ |
| អភិវឌ្ឍន៍ជនបទ | ១២ | ៤ ៤៨៨,២ | ១ ១០៤,១ |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | ៤ | ១ ៤៩៦,១ | ៣៦៨,០ |
| **សរុប** | **២៤** | **៨ ៩៧៦,៥** | **២ ២០៨,២** |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | |
| ដឹកជញ្ជូន (ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាសចរណ៍) | ១២ | ៤ ៤៨៨,២ | ១ ១០៤,១ |
| ទឹកនិងអនាម័យ (មិនគិតនៅជនបទ) | ៤ | ១ ៤៩៦,១ | ៣៦៨,០ |
| ថាមពលនិងអគ្គិសនី | ៤ | ១ ៤៩៦,១ | ៣៦៨,០ |
| ប្រៃសណីយ៍និងទូរគមនាគមន៍ | ១ | ៣៧៤,០ | ៩២,០ |
| **សរុប** | **២១** | **៨ ៨៥៤,៤** | **១ ៩៣២,២** |
| **សេវាកម្មនិងកម្មវិធីអន្តរវិស័យ** | | | |
| ការបញ្ជ្រាបយេនឌ័រ | ១,៥ | ៥៦១,០ | ១៣៨,០ |
| ទេសចរណ៍ | ២ | ៧៤៨,០ | ១៨៧,០ |
| បរិស្ថាននិងការអភិវឌ្ឍ | ៤ | ១ ៤៩៦,១ | ៣៦៨,០ |
| សហគមន៍និងសេវាកម្មសង្គម | ៤ | ១ ៤៩៦,១ | ៣៦៨,០ |

| | | | |
|---|---|---|---|
| វប្បធម៌និងសិល្បៈ | ១,៥ | ៥៦១,០ | ១៣៨,០ |
| អភិបាលកិច្ចនិងរដ្ឋបាល | ៨ | ២ ៩៩២,២ | ៧ ៣៦,១ |
| **សរុប** | **២១** | **៨ ៨៥៤,៤** | **១ ៩៣២,២** |
| មិនទាន់បែងចែក | ២ | ៧៤៨,០ | ១៨៤,០ |
| **សរុបរួម** | **១០០** | **៣៧ ៤០២,១** | **៩ ២០១,០** |

ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងផែនការ

# ជំពូកទី៣

## កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០២២-២០២៤

២៩- ដូចបានបង្ហាញក្នុងជំពូកមុនដែរ សម្រាប់ការអនុវត្ត*ផ.យ.អ.ជ.២០១៩-២០២៣*(រយៈពេល៥ឆ្នាំ) រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការប៉ាន់ស្មានតម្លៃសរុបចំនួន៩៥ ៥២៧,៥ប៊ីលានរៀល(២៣ ៥០០លានដុល្លារអាម៉េរិក) សម្រាប់បំពេញតម្រូវការវិនិយោគវិស័យសាធារណៈ ដើម្បីសម្រេចបាននូវការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលនីតិកាលទី៦។ ការវិភាជសម្រាប់*ក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤* មានចំនួន៣៧ ៤០២,១ប៊ីលានរៀល(៩ ២០១,០លានដុល្លារអាម៉េរិក) (តារាងទី៧) និងដូចមានចែងនៅក្នុងក្របខ័ណ្ឌចំណាយសម្រាប់រយៈពេលមធ្យម គឺរាជរដ្ឋាភិបាលកម្ពុជាបានវិភាជថវិកាជាតិចំនួន១៦ ២២៧,៥ប៊ីលានរៀល(៣ ៩៩២,០លានដុល្លារអាម៉េរិក) សម្រាប់*ក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤*។

**តារាងទី៧ : ការវិភាជតាមវិស័យនិងអនុវិស័យ សម្រាប់តម្រូវការវិនិយោគវិស័យសាធារណៈ ចែងនៅក្នុងផ.យ.អ.ជ.២០១៩-២០២៣ និងក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤**

| វិស័យនិងអនុវិស័យ | គោលដៅវិនិយោគសាធារណៈក្នុងផ.យ.អ.ជ.២០១៩-២០២៣ | | | | | |
|---|---|---|---|---|---|---|
| | ផ.យ.អ.ជ.២០១៩-២០២៣ | | | ក.វ.ស.២០២២-២០២៤ | | |
| | ភាគរយ | ប៊ីលានរៀល | លានដុល្លារអាម៉េរិក | ប៊ីលានរៀល | លានដុល្លារអាម៉េរិក | ភាគរយ |
| **វិស័យសង្គមកិច្ច** | | | | | | |
| អប់រំ : ក្នុងនោះការអប់រំមូលដ្ឋាន៦០% | ១០ | ៩ ៥៥២,៨ | ២ ៣៥០,០ | ៣ ៧៤០,២ | ៩២០,១ | ១០ |
| បច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៨ | ៧ ៦៤២,២ | ១ ៨៨០,០ | ២ ៩៩២,២ | ៧ ៣៦,១ | ៨ |
| សុខាភិបាល | ១០ | ៩ ៥៥២,៨ | ២ ៣៥០,០ | ៣ ៧៤០,២ | ៩២០,១ | ១០ |
| កម្មវិធីគាំពារសង្គម/ការកាត់បន្ថយភាពក្រីក្រ | ៤ | ៣ ៨២១,១ | ៩៤០,០ | ១ ៤៩៦,១ | ៣៦៨,០ | ៤ |
| **សរុប** | **៣២** | **៣០ ៥៦៨,៨** | **៧ ៥២០,០** | **១១ ៩៦៨,៧** | **២ ៩៤៤,៣** | **៣២** |
| **វិស័យសេដ្ឋកិច្ច** | | | | | | |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី | ៤ | ៣ ៨២១,១ | ៩៤០,០ | ១ ៤៩៦,១ | ៣៦៨,០ | ៤ |
| ដំណាំតាមរដូវ : ស្រូវនិងដំណាំផ្សេងៗ | ៤ | ៣ ៨២១,១ | ៩៤០,០ | ១ ៤៩៦,១ | ៣៦៨,០ | ៤ |
| អភិវឌ្ឍន៍ជនបទ | ១២ | ១១ ៤៦៣,៣ | ២ ៨២០,០ | ៤ ៤៨៨,២ | ១ ១០៤,១ | ១២ |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | ៤ | ៣ ៨២១,១ | ៩៤០,០ | ១ ៤៩៦,១ | ៣៦៨,០ | ៤ |
| **សរុប** | **២៤** | **២២ ៩២៦,៦** | **៥ ៦៤០,០** | **៨ ៩៧៦,៥** | **២ ២០៨,២** | **២៤** |

| | | | | | | |
|---|---|---|---|---|---|---|
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | | | | |
| ដឹកជញ្ជូន (ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាសចរណ៍) | ១២ | ១១ ៤៦៣,៣ | ២ ៨២០,០ | ៤ ៤៨៨,២ | ១ ១០៤,១ | ១២ |
| ទឹកនិងអនាម័យ (មិនគិតនៅជនបទ) | ៤ | ៣ ៨២១,១ | ៩៤០,០ | ១ ៤៩៦,១ | ៣៦៨,០ | ៤ |
| ថាមពលនិងអគ្គិសនី | ៤ | ៣ ៨២១,១ | ៩៤០,០ | ១ ៤៩៦,១ | ៣៦៨,០ | ៤ |
| ប្រៃសណីយ៍និងទូរគមនាគមន៍ | ១ | ៩៥៥,៣ | ២៣៥,០ | ៣៧៤,០ | ៩២,០ | ១ |
| **សរុប** | **២១** | **២០ ០៦០,៨** | **៤ ៩៣៥,០** | **៨ ៨៥៤,៤** | **១ ៩៣២,២** | **២១** |
| **សេវានិងកម្មវិធីអន្តរវិស័យ** | | | | | | |
| ការបញ្ជ្រាបយេនឌ័រ | ១,៥ | ១ ៤៣២,៩ | ៣៥២,៥ | ៥៦១,០ | ១៣៨,០ | ១,៥ |
| ទេសចរណ៍ | ២ | ១ ៩១០,៦ | ៤៧០,០ | ៧៤៨,០ | ១៨៤,០ | ២ |
| បរិស្ថាននិងការអភិវឌ្ឍ | ៤ | ៣ ៨២១,១ | ៩៤០,០ | ១ ៤៩៦,១ | ៣៦៨,០ | ៤ |
| សហគមន៍និងសេវាកម្មសង្គម | ៤ | ៣ ៨២១,១ | ៩៤០,០ | ១ ៤៩៦,១ | ៣៦៨,០ | ៤ |
| វប្បធម៌និងសិល្បៈ | ១,៥ | ១ ៤៣២,៩ | ១ ៤៤៥,៣ | ៥៦១,០ | ១៣៨,០ | ១,៥ |
| អភិបាលកិច្ចនិងរដ្ឋបាល | ៨ | ៧ ៦៤២,២ | ១ ៨៨០,០ | ២ ៩៩២,២ | ៧ ៣៦,១ | ៨ |
| **សរុប** | **២១** | **២០ ០៦០,៨** | **៤ ៩៣៥,០** | **៨ ៨៥៤,៤** | **១ ៩៣២,២** | **២១** |
| **មិនទាន់បែងចែក** | **២** | **១ ៩១០,៦** | ៤៧០,០ | ៧៤៨,០ | ១៨៤,០ | **២** |
| **សរុបរួម** | **១០០** | **៩៥ ៥២៧,៥** | **២៣ ៥០០,០** | **៣៧ ៤០២,១** | **៩ ២០១,០** | **១០០** |

ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងផែនការ

## ក- សេចក្តីសង្ខេបនៃគម្រោងសម្រាប់ក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤ ដែលបានទទួលពីក្រសួង ស្ថាប័ន

៣០- *ក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤* បានរៀបចំឡើងដោយមានមូលដ្ឋានលើធាតុចូលដែលបានទទួលពីគ្រប់ក្រសួងស្ថាប័ន រួមមាន: *(១)គម្រោងកំពុងដំណើរការ* ជាគម្រោងដែលកំពុងអនុវត្តដោយមានកិច្ចសហការប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និង*(២)គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.(គម្រោងថ្មី)* ដែលក្រសួងស្ថាប័នមានគម្រោងអនុវត្តក្នុងកំលុងពេលឆ្នាំ២០២២-២០២៤។ *ផ.យ.អ.ជ.២០១៩-២០២៣* បានចែងថា បរិមាណថវិកាចំនួន២៣ ៥០០លានដុល្លារអាម៉េរិកនឹងត្រូវចំណាយសម្រាប់តម្រូវការវិនិយោគវិស័យសាធារណៈសម្រាប់រយៈពេល៥ឆ្នាំ២០១៩-២០២៣ ចំណែកឯតម្រូវការវិនិយោគវិស័យសាធារណៈនៃ*ក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤* មានចំនួន៩ ២០១,០លានដុល្លារអាម៉េរិក។ ព័ត៌មានសង្ខេបស្តីពីគម្រោង *ក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤* ដែលបានស្នើឡើងដោយក្រសួងស្ថាប័នមានបង្ហាញនៅក្នុងតារាងទី៨៖

- តម្រូវការចំណាយប៉ាន់ស្មានសរុបសម្រាប់*ក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤* តម្រូវការថវិកាសរុប៩ ២០១,០លានដុល្លារអាម៉េរិក។
  - គម្រោងកំពុងដំណើរការ ៥ ៨១៧,០លានដុល្លារអាម៉េរិក
  - គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.(ថ្មី) ៣ ៣៨៤,០លានដុល្លារអាម៉េរិក
- បរិមាណថវិកាដែលក្រសួងស្ថាប័នបានរាយការណ៍ថា បានសន្យាផ្ដល់៧ ៧១៣,៣លានដុល្លារអាម៉េរិក
  - ថវិកាជាតិ ៤៧៧,១លានដុល្លារអាម៉េរិក
  - ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ៧ ២៣៦,២លានដុល្លារអាម៉េរិក
    - សម្រាប់គម្រោងកំពុងដំណើរការ ៥ ៥១៧,១លានដុល្លារអាម៉េរិក
      - ថវិកាជាតិ ៤២០,៣លានដុល្លារអាម៉េរិក
      - ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ៥ ០៩៦,៨លានដុល្លារអាម៉េរិក
    - សម្រាប់គម្រោងអនុវត្តផ.យ.អ.ជ.(ថ្មី) ២ ១៩៦,១លានដុល្លារអាម៉េរិក
      - ថវិកាជាតិ ៥៦,៨លានដុល្លារអាម៉េរិក
      - ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ២ ១៣៩,៣លានដុល្លារអាម៉េរិក
- តម្រូវការថវិកាបំពេញបន្ថែម(បំពេញបន្ថែមលើបរិមាណហិរញ្ញប្បទានដែលបានសន្យា) ១ ៤៨៧,៧លានដុល្លារអាម៉េរិក
  - គម្រោងកំពុងដំណើរការ ២៩៩,៩នដុល្លារអាម៉េរិក
  - គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ១ ១៨៧,៨លានដុល្លារអាម៉េរិក

៣១- តារាងទី៩នឹងធ្វើការបង្ហាញលម្អិតបន្ថែមនូវគម្រោងដែលក្រសួងស្ថាប័នទាំងអស់បានផ្ញើមកក្រសួងផែនការសម្រាប់ធ្វើការរៀបចំ*ក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤*និងបានបែងចែកគម្រោងទាំងអស់នោះទៅតាមវិស័យអាទិភាពរបស់*ផ.យ.អ.ជ.២០១៩-២០២៣*។ ព័ត៌មានគម្រោងទាំងនោះ រួមមាន : (១)តម្រូវការចំណាយប៉ាន់ស្មានសរុបទៅតាមឆ្នាំនីមួយៗពីឆ្នាំ២០២២ដល់ឆ្នាំ២០២៤ (២)បរិមាណហិរញ្ញប្បទានដែលក្រសួងស្ថាប័នបានរាយការណ៍ថាបានសន្យាផ្ដល់(ដោយរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ) សម្រាប់គម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. និង(៣)បរិមាណតម្រូវការហិរញ្ញប្បទានបំពេញបន្ថែមលើហិរញ្ញប្បទានដែលបានសន្យាផ្ដល់រួចហើយក្នុងឆ្នាំនីមួយៗ។

## តារាងទី៨ : សេចក្តីសង្ខេបស្តីពីគម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ដែលក្រសួងស្ថាប័នស្នើសុំសម្រាប់ក.វ.ស.៣ឆ្នាំរំកិល២០២២-២០២៤

(គិតជាពាន់ដុល្លារអាមេរិក)

| | ចំណាយប៉ាន់ស្មានសរុប | | | | ហិរញ្ញប្បទានបានសន្យាផ្តល់ | | | | | តម្រូវការហិរញ្ញប្បទានបំពេញបន្ថែម | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២២ | ២០២៣ | ២០២៤ | សរុប ២០២២-២០២៤ | ប្រភពហិរញ្ញប្បទាន | ២០២២ | ២០២៣ | ២០២៤ | សរុប ២០២២-២០២៤ | ២០២២ | ២០២៣ | ២០២៤ | សរុប ២០២២-២០២៤ |
| គម្រោងកំពុងដំណើរការ | 2,840,000.0 | 2,183,000.0 | 794,000.0 | 5,817,000.0 | រាជរដ្ឋាភិបាល | 161,227.2 | 155,140.8 | 103,895.9 | 420,263.9 | 89,990.0 | 99,494.1 | 110,405.8 | 299,889.9 |
| | | | | | ដៃគូអភិវឌ្ឍ | 2,588,782.8 | 1,928,365.1 | 579,698.3 | 5,096,846.2 | | | | |
| | | | | | សរុប | 2,750,010.0 | 2,083,505.9 | 683,594.2 | 5,517,110.1 | | | | |
| គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ | 858,000.0 | 1,156,000.0 | 1,370,000.0 | 3,384,000.0 | រាជរដ្ឋាភិបាល | 22,078.3 | 18,115.5 | 16,635.1 | 56,828.9 | 400,470.6 | 385,365.8 | 402,022.3 | 1,187,858.7 |
| | | | | | ដៃគូអភិវឌ្ឍ | 435,451.1 | 752,518.7 | 951,342.6 | 2,139,312.4 | | | | |
| | | | | | សរុប | 457,529.4 | 770,634.2 | 967,977.7 | 2,196,141.3 | | | | |
| សរុប | 3,698,000.0 | 3,339,000.0 | 2,164,000.0 | 9,201,000.0 | រាជរដ្ឋាភិបាល | 183,305.5 | 173,256.3 | 120,531.0 | 477,092.8 | 490,460.6 | 484,859.9 | 512,428.1 | 1,487,748.6 |
| | | | | | ដៃគូអភិវឌ្ឍ | 3,024,233.9 | 2,680,883.8 | 1,531,040.9 | 7,236,158.6 | | | | |
| | | | | | សរុប | 3,207,539.4 | 2,854,140.1 | 1,651,571.9 | 7,713,251.4 | | | | |

## តារាងទី៩ : សេចក្តីសង្ខេបស្តីពីគម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. បែងចែកទៅតាមវិស័យអាទិភាពនៃ២០១៩-២០២៣ ដែលក្រសួងស្ថាប័នស្នើសុំ

(គិតជាពាន់ដុល្លារអាមេរិក)

| ក្រសួង ស្ថាប័ន | ចំណាយប៉ាន់ស្មានសរុប | | | | ហិរញ្ញប្បទានដែលបានសន្យាផ្តល់ | | | | | តម្រូវការហិរញ្ញប្បទានបំពេញបន្ថែម | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២២ | ២០២៣ | ២០២៤ | សរុប ២០២២-២០២៤ | ប្រភពហិរញ្ញប្បទាន | ២០២២ | ២០២៣ | ២០២៤ | សរុប ២០២២-២០២៤ | ២០២២ | ២០២៣ | ២០២៤ | សរុប ២០២២-២០២៤ |
| **វិស័យសង្គមកិច្ច** | | | | | | | | | | | | | |
| **គម្រោងកំពុងដំណើរការ** | 338,309.2 | 231,761.3 | 166,116.3 | 736,186.8 | សរុប | 273,111.8 | 151,922.7 | 61,674.9 | 486,709.4 | 65,197.4 | 79,838.6 | 104,441.4 | 249,477.4 |
| | | | | | រាជរដ្ឋាភិបាល | 24,414.2 | 27,129.9 | 14,243.6 | 65,787.7 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 248,697.6 | 124,792.8 | 47,431.3 | 420,921.7 | | | | |
| **គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.** | 99,108.6 | 112,064.6 | 136,563.6 | 347,736.8 | សរុប | 88,079.5 | 95,189.4 | 116,758.4 | 300,027.3 | 11,029.1 | 16,875.2 | 19,805.2 | 47,709.5 |
| | | | | | រាជរដ្ឋាភិបាល | 13,479.5 | 13,479.4 | 13,479.4 | 40,438.3 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 74,600.0 | 81,710.0 | 103,279.0 | 259,589.0 | | | | |
| **សរុប** | 437,417.8 | 343,825.9 | 302,679.9 | 1,083,923.6 | សរុប | 361,191.3 | 247,112.1 | 178,433.3 | 786,736.7 | 76,226.5 | 96,713.8 | 124,246.6 | 297,186.9 |
| | | | | | រាជរដ្ឋាភិបាល | 37,893.7 | 40,609.3 | 27,723.0 | 106,226.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 323,297.6 | 206,502.8 | 150,710.3 | 680,510.7 | | | | |
| **១- ក្រសួងសុខាភិបាល** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 204,197.5 | 138,718.0 | 107,910.2 | 450,825.7 | សរុប | 149,501.1 | 77,942.4 | 40,651.8 | 268,095.3 | 54,696.4 | 60,775.6 | 67,258.4 | 182,730.4 |
| | | | | | រាជរដ្ឋាភិបាល | 15,926.8 | 17,629.2 | 10,675.1 | 44,231.1 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 133,574.3 | 60,313.2 | 29,976.7 | 223,864.2 | | | | |
| គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. | 50,249.7 | 43,409.7 | 61,028.7 | 154,688.1 | សរុប | 49,538.6 | 42,648.5 | 60,117.5 | 152,304.6 | 711.1 | 761.2 | 911.2 | 2,383.5 |
| | | | | | រាជរដ្ឋាភិបាល | 38.6 | 38.5 | 38.5 | 115.6 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 49,500.0 | 42,610.0 | 60,079.0 | 152,189.0 | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សរុប | 254,447.2 | 182,127.7 | 168,938.9 | 605,513.8 | សរុប | 199,039.7 | 120,590.9 | 100,769.3 | 420,399.9 | 55,407.5 | 61,536.8 | 68,169.6 | 185,113.9 |
| | | | | | រាជរដ្ឋាភិបាល | 15,965.4 | 17,667.7 | 10,713.6 | 44,346.7 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 183,074.3 | 102,923.2 | 90,055.7 | 376,053.2 | | | | |
| **២- ក្រសួងអប់រំ យុវជន និងកីឡា** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 81,272.2 | 45,983.3 | 14,145.5 | 141,401.0 | សរុប | 81,272.2 | 45,983.3 | 14,145.5 | 141,401.0 | - | - | - | - |
| | | | | | រាជរដ្ឋាភិបាល | 1,433.4 | 950.7 | 758.5 | 3,142.6 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 79,838.8 | 45,032.6 | 13,387.0 | 138,258.4 | | | | |
| គម្រោងសម្រាប់អនុវត្តជ.យ.អ.ជ. | 31,400.0 | 41,500.0 | 35,980.0 | 108,880.0 | សរុប | 25,100.0 | 29,100.0 | 23,200.0 | 77,400.0 | 6,300.0 | 12,400.0 | 12,780.0 | 31,480.0 |
| | | | | | រាជរដ្ឋាភិបាល | - | - | - | - | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 25,100.0 | 29,100.0 | 23,200.0 | 77,400.0 | | | | |
| សរុប | 112,672.2 | 87,483.3 | 50,125.5 | 250,281.0 | សរុប | 106,372.2 | 75,083.3 | 37,345.5 | 218,801.0 | 6,300.0 | 12,400.0 | 12,780.0 | 31,480.0 |
| | | | | | រាជរដ្ឋាភិបាល | 1,433.4 | 950.7 | 758.5 | 3,142.6 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 104,938.8 | 74,132.6 | 36,587.0 | 215,658.4 | | | | |
| **៣- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 16,339.5 | 9,760.0 | 6,060.6 | 32,160.1 | សរុប | 16,339.5 | 9,760.0 | 6,060.6 | 32,160.1 | - | - | - | - |
| | | | | | រាជរដ្ឋាភិបាល | 2,804.0 | 2,800.0 | 2,810.0 | 8,414.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 13,535.5 | 6,960.0 | 3,250.6 | 23,746.1 | | | | |
| គម្រោងសម្រាប់អនុវត្តជ.យ.អ.ជ. | 17,458.9 | 27,154.9 | 39,554.9 | 84,168.7 | សរុប | 13,440.9 | 23,440.9 | 33,440.9 | 70,322.7 | 4,018.0 | 3,714.0 | 6,114.0 | 13,846.0 |
| | | | | | រាជរដ្ឋាភិបាល | 13,440.9 | 13,440.9 | 13,440.9 | 40,322.7 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | - | 10,000.0 | 20,000.0 | 30,000.0 | | | | |
| សរុប | 33,798.4 | 36,914.9 | 45,615.5 | 116,328.8 | សរុប | 29,780.4 | 33,200.9 | 39,501.5 | 102,482.8 | 4,018.0 | 3,714.0 | 6,114.0 | 13,846.0 |
| | | | | | រាជរដ្ឋាភិបាល | 16,244.9 | 16,240.9 | 16,250.9 | 48,736.7 | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ដៃគូអភិវឌ្ឍ | 13,535.5 | 16,960.0 | 23,250.6 | 53,746.1 | | | | |
| **៤- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 36,500.0 | 37,300.0 | 38,000.0 | 111,800.0 | សរុប | 25,999.0 | 18,237.0 | 817.0 | 45,053.0 | 10,501.0 | 19,063.0 | 37,183.0 | 66,747.0 |
| | | | | | រាជរដ្ឋាភិបាល | 4,250.0 | 5,750.0 | - | 10,000.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 21,749.0 | 12,487.0 | 817.0 | 35,053.0 | | | | |
| គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. | - | - | - | - | សរុប | - | - | - | - | - | - | - | - |
| | | | | | រាជរដ្ឋាភិបាល | - | - | - | - | | | | |
| | | | | | ដៃគូអភិវឌ្ឍ | - | - | - | - | | | | |
| សរុប | 36,500.0 | 37,300.0 | 38,000.0 | 111,800.0 | សរុប | 25,999.0 | 18,237.0 | 817.0 | 45,053.0 | 10,501.0 | 19,063.0 | 37,183.0 | 66,747.0 |
| | | | | | រាជរដ្ឋាភិបាល | 4,250.0 | 5,750.0 | - | 10,000.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 21,749.0 | 12,487.0 | 817.0 | 35,053.0 | | | | |
| **វិស័យសេដ្ឋកិច្ច** | | | | | | | | | | | | | |
| **គម្រោងកំពុងដំណើរការ** | 982,294.2 | 745,824.7 | 421,611.4 | 2,149,730.3 | សរុប | 959,317.5 | 726,813.4 | 415,647.0 | 2,101,777.9 | 22,976.7 | 19,011.3 | 5,964.4 | 47,952.4 |
